# សត្វក្ងោក

(ភុជង្គលីលា)

ខ្ញុំកើតជាធម្មតា ត្រកូលវង្សា ពូជពង្សផងខ្លួនខ្ញុំសោះ។
ម្ដេចថាពូជមិនស្មោះ មានស្នេហ៍ឡេះឡោះ អំបូលផិតក្បត់សាវ៉ា។
នឹកទៅឃោឃៅអស្ចារ្យ អ្នកមានមាត់ថា ថាបានតាមចិត្តតាមចង់។
ក្ងោកខ្ញុំទឹកភ្នែករហាង់ ទោះខ្ញុំមិនចង់ កង់កម្មវង់វិលឥតប្រែ។
ទោះខ្ញុំប្រឹងស្រែកឡែៗ ក៏គង់ដដែល កែកុនមិនបានសោះឡើយ។
ខ្ញុំសួរគេមិនដែលឆ្លើយ ខ្ញុំហៅគេហើយ គេមិនព្រមស្ដាប់ឮទេ។
បើឮគេបកមកជេរ ខ្ញុំទទួលទ្វេ បន្ថែមគេដាក់ទោសា។
ទោះខ្ញុំមិនខុសឡើយណា ធ្វើម៉េចគេថា ខ្ញុំខុសជាក់ច្បាស់ទៅហើយ។
បើចង់សុខសាន្តបានស្បើយ រកផ្លូវឃើញហើយ ស្រែកល្អល្អល្អល្អល្អ។
ដូច្នេះម្ល៉េះខ្ញុំបន្ត ត្រកូលរងសរ ឈាមកកដល់កល្អណាស់។
ខ្ញុំព្រមថាល្អឥតផ្លាស់ ល្អណាស់ៗ ល្អគ្មានអ្នកប្រដូចទេ។

ភ្នំពេញ ថ្ងៃទី២៨ កញ្ញា ២០០៥

សូយ ឡូយ